អង្គរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## ក្រោមប្រធានបទ របៀបចំរើនសមថកម្មដ្ឋាន (ត)

website ៖ www.hoksavann.org

ថ្ងៃទី៨ សីហា ២០០៨



### របៀបចំរើនអសុភកម្មដ្ឋាន

ការចំរើនអសុភកម្មដ្ឋាន គឺដើម្បីផ្ចាញ់នូវបុគ្គលដែលរាគចរិត ។ ពាក្យថាអសុភនេះ មិនមែនប្រើថាខ្មោចទេ គឺប្រែថាគ្រឿងឬវត្ថុមិនស្អាត ។ អសុភមាន១០ មានឧទ្ធុកមាតកអសុភ ដែលប្រែថាអសុភហើមប៉ោងរបូតអង្គិកអសុភដែលប្រែថា អសុភមានតែរាងឆ្អឹងជាដើម ។ អសុភមានប្រភេទខុសគ្នារហូតដល់១០ គឺគេឲ្យឈ្មោះទៅតាមរយៈសាកសពដែលគេយកទៅចោល ព្រោះសាកសពតែងប្រែប្រួលទ្រង់ទ្រាយពណ៌សម្បុរទៅតាមរយៈពេល ឧទាហរណ៍សាកសពទុកចោលយូរឆ្នាំ វារលួយអស់សាច់នៅសល់តែរាងឆ្អឹងជាដើម ។ ប្រភេទអសុភទាំង១០នោះគួរយកធ្វើជាអារម្មណ៍កម្មដ្ឋានបាន ។ កាលពីសម័យបូរាណបុគ្គលអ្នកចំរើនទៅពិនិត្យមើលសាកសព ដែលគេយកទៅចោលក្នុងព្រៃស្មសានជាទីស្ងប់ស្ងាត់ ដែលមិនសូវមានមនុស្សទៅ ដែលគេហៅថាព្រៃចោលខ្មោច ។ ក្នុងការពិនិត្យមើលនោះ គេមិនឲ្យឈរឆ្ងាយពេកឬជិតពេក កុំឈរបណ្ដោយខ្យល់ឬច្រាសខ្យល់ ហើយឲ្យពិនិត្យមើលសាកសពមានភេទដូចគ្នា គឺបើបុគ្គលអ្នកចំរើនប្រុសឲ្យពិនិត្យមើលសាកសពប្រុស បើអ្នកចំរើនស្រីឲ្យពិនិត្យមើលសាកសពណាស្រី ព្រោះបើមានភេទផ្ទុយគ្នាខ្លាចក្រែងកើតតម្រេកនៅពេលពិនិត្យមើល ។ ពេលចំរើនអសុភនោះ បើឃើញនិមិត្តអសុភនោះជាប់នឹងភ្នែក ឈ្មោះថាឧគ្គហនិមិត្តកើតឡើងហើយ ប៉ុន្តែមិនទាន់បានសំរេចផលក្នុងចំរើនអសុភនេះទេ លុះត្រា

តែបដិភាគនិមិត្តកើតឡើង ឃើញភាគមិនស្អាតនៃអសុភ ទើបបានសំរេចផលក្នុងការចំរើនអសុភនេះ ព្រោះឃើញភាពមិនស្អាតនៃសាកសពនោះ ទើបរាគៈថយ ស្របនឹងពាក្យថាអសុភ ប្រែថាសាកសពមិនស្អាតគួរខ្ពើមរអើម ។ ការជាប់ចិត្តស្រឡាញ់ ព្រោះសំគាល់ថាស្អាតថាល្អ ។ ដូច្នេះ ការឃើញអសុភសញ្ញាសំគាល់ថាមិនស្អាត ទើបបានសំរេចផលក្នុងអសុភកម្មដ្ឋាននេះ ដែលជាហេតុធ្វើឲ្យការជាប់ចិត្តស្រឡាញ់ ត្រូវថយចុះជាលំដាប់ ពុំមែនភាវនាទៅឃើញរូបអសុភ ថាបានសម្រេចអសុភកម្មដ្ឋានហើយនោះទេ ។ ដូចជាអាចារ្យយោគីដុតខ្មោច ហេតុអ្វីបានជាគាត់មិនបានសំរេចក្នុងអសុភកម្មដ្ឋាននេះ ព្រោះគាត់មិនបានតាំងចិត្តពិចារណាឲ្យឃើញភាពមិនស្អាតនៃអសុភទាំងនោះ មុខងាររបស់គាត់គឺដុតសាកសពដើម្បីយកថ្លៃឈ្នួលប៉ុណ្ណោះ ។ អសុភកម្មដ្ឋាននេះបើព្យាយាមឲ្យបានខ្លាំងក្លា អាចសំរេចដល់អប្បនាឈាន តែបានត្រឹមតែបឋមជ្ឈានមិនអាចសំរេចដល់ឈានថ្នាក់លើទៀតឡើយ ។

## របៀបចំរើនកាយគតាសតិ

កាយគតាសតិប្រែថា ការពិចារណានូវអាការៈក្នុងកាយ ។ កាយគតាសតិនេះ ក៏សំរាប់ផ្ចាញ់នូវរាគៈ ដូចជាអសុភកម្មដ្ឋានដែរ ។ កម្មដ្ឋាននេះ បុគ្គលត្រូវពិចារណាអាការៈ៣២នៅក្នុងរូបរាងកាយរបស់មនុស្សសត្វ ជាពិសេសរបស់ខ្លួនឯង ។ អាការៈ៣២នោះមានតែអាការៈ៥ទេ ដែលនៅខាងក្រៅបុគ្គលអ្នកចំរើនអាចមើលឃើញដោយផ្ទាល់ភ្នែកចំណែកអាការៈក្រៅពីនេះ លុះត្រាតែបានស្តាប់គ្រូពន្យល់ទើបចំរើនបាន ។ អាការៈទាំង៥នោះ គឺកេសា សក់ទាំងឡាយ លោមា រោមទាំងឡាយ នខា ក្រចកទាំងឡាយ ទន្តា ធ្មេញទាំងឡាយ និង តចោស្បែក ។ អាការៈ៥នេះហើយ ដែលឧបជ្ឈាយ៍បំបួសសាមណេរឲ្យកុលបុត្រដែលបួសឲ្យពិចារណាថា អាការៈទាំងនេះជារបស់ បដិកូល ហៅថា តចបញ្ចកកម្មដ្ឋាន ។ បានជាព្រះឧបជ្ឈាយ៍ឲ្យកុលបុត្រពិចារណានូវអាការៈទាំង៥នេះ ថាជាបដិកូលមិនស្អាតនៅពេលចាប់ផ្តើមបួស គឺដើម្បីឲ្យកុលបុត្រនោះដកចិត្តពីការស្រឡាញ់ជាប់ចិត្តនឹងអ្វីមួយ ជាពិសេសជាប់ចិត្តនឹងខ្លួនឯង ទើបបួសបាន ដោយពាក្យថានេក្ខម្មៈ គឺការចេញចាកកាមគុណ៥មានរូបជាដើម ។ ចំពោះការចំរើនកាយគតាសតិប្រកបដោយអាការៈ៣២នេះ គឺពិចារណាឲ្យឃើញបដិកូលដោយ

ស្ថាន៥យ៉ាងគឺ ៖ ១- វណ្ណតោ បដិកូលដោយពណ៌, ២- សណ្ឋានតោ បដិកូលដោយសណ្ឋានគឺដោយទ្រង់ទ្រាយ, ៣- គន្ធតោ បដិកូលដោយក្លិន, ៤- អាសយតោ បដិកូលដោយទីអាស្រ័យនៅ, ៥- ឱកាសតោ បដិកូល ដោយឱកាសដែលប្រតិស្ឋាននៅ ។ សូមលើកធ្វើជាឧបករណ៍នូវអាការៈមួយគឺសក់ ។ ១- សក់មានពណ៌ខ្មៅ ពណ៌លឿង ពណ៌ស ស្របទៅតាមជាតិ ស្របតាមវ័យ, ២- សក់មានរាងមូលតូចឆ្មារ, ៣- សក់មានក្លិនអាក្រក់ បើគេមិនបានថែទាំវាទេ, ៤- សក់ស្ថិតនៅលើក្បាល, ៥- សក់ដុះចេញពីស្បែកក្បាលប្រកបដោយខ្ទុះឈាម ។ អាការៈទាំង៣២នេះ ត្រូវពិចារណាឲ្យឃើញបដិកូលដោយស្ថាន៥យ៉ាងនេះដូចគ្នា ។ កាលបើកុលបុត្រពិចារណាឲ្យរឿយៗ អាការៈទាំង៣២នេះ កើតប្រាកដឡើងជាឧគ្គហនិមិត្ត ហើយបដិភាគនិមិត្តកើតឡើងឃើញអាការៈ៣២នេះមិនស្អាតគួរខ្ពើមរអើម។ កាយគតាសតិកម្មដ្ឋាននេះអាចកើតឡើងឃើញអាការៈ៣២នេះមិនស្អាតគួរខ្ពើមរអើម ។ កាយគតាសតិកម្មដ្ឋាននេះ អាចកើតដល់អប្បនាចិត្ត តែបានត្រឹមតែបឋមជ្ឈាន ដូចជាអសុភកម្មដ្ឋានដែរ ។៚

❇ ❇

❇